# បទអន្តរាគមន៍
# របស់ឯកឧត្តម ជៀង អំ អភិបាលខេត្តស្វាយរៀង
# ក្នុងសន្និសីទ ស្តីពី ចក្ខុវិស័យកម្ពុជា ឆ្នាំ២០០៧
# ដែលរៀបចំឡើងដោយវិទ្យាស្ថាន CDRI និងធនាគារ ANZ Royal
# នាថ្ងៃទី ២២-២៣ ខែ កុម្ភៈ ឆ្នាំ២០០៧

-សូមគោរពគណៈអធិបតី ជាទីគោរពដ៏ខ្ពង់ខ្ពស់ !

-សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី ភ្ញៀវជាតិ អន្តរជាតិ ជាទីគោរព !

-សមាជិក សមាជិកា នៃអង្គសន្និសីទទាំងមូល ជាទីមេត្រី !

ថ្ងៃនេះ ខ្ញុំមានកិត្តិយសដ៏ឧត្តុង្គឧត្តមបំផុត ក្នុងនាមអភិបាលខេត្តស្វាយរៀង ខ្ញុំសូមសំដែងនូវមនោសញ្ចេតនារំភើបរីករាយ ដោយបានមកចូលរួមក្នុងសន្និសីទ ស្តីពី ចក្ខុវិស័យកម្ពុជាឆ្នាំ២០០៧ ដែលរៀបចំឡើងដោយវិទ្យាស្ថានCDRI និងធនាគារ ANZ Royal និងសូមប្រសិទ្ធិពរដល់អង្គសន្និសីទទាំងមូល មានដំណើរការប្រព្រឹត្តិទៅប្រកបដោយជោគជ័យ ។

*អង្គសន្និសីទទាំងមូល ជាទីមេត្រី !*

ខេត្តស្វាយរៀង គឺជាខេត្តមួយស្ថិតនៅភាគអគ្នេយ៍ នៃរាជធានីភ្នំពេញ មានចំងាយប្រមាណ ១២៥គ.ម ហើយតំបន់រដ្ឋបាលខេត្តមានផ្ទៃដី ២៩៦.៦៤០ហិកតា ចែកចេញជា ០៧ស្រុក ៨០ឃុំ ៦៩០ភូមិ និងមានព្រំប្រទល់ជាប់នឹងប្រទេសវៀតណាមប្រវែងប្រមាណ ២៥៨គ.ម ជាខេត្តដែលមានលក្ខណៈភូមិសាស្ត្រ ជាតំបន់វាលរាប ។ ខេត្តមានច្រកទ្វារព្រំដែនសំខាន់ៗ ចំនួន ០៥កន្លែង គឺ : ច្រកទ្វារព្រំដែនអន្តរជាតិបាវិត ច្រកទ្វារព្រំដែនទ្វេរភាគីព្រៃវល្លិ៍ និងច្រកទ្វារតំបន់ព្រំដែន ០៣ គឺ បុសមន ស្រែបារាំង និងសំរោង ។ មានប្រជាពលរដ្ឋ សរុប ចំនួន ១១១.៦១១គ្រួសារ មានមនុស្ស ចំនួន ៥៣៦.៩៦៣នាក់ ហើយស្ថានភាពជីវភាពរស់នៅរបស់ប្រជាជនជាង ៩០% ពឹងផ្អែកទៅលើផលរបរកសិកម្មជាមូលដ្ឋាន ។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំសូមចូលរួមយោបល់ពិភាក្សា ក្រោមប្រធានបទ ស្តីពី **"ជំរុញសន្ទុះក្បាលម៉ាស៊ីន កំណើន និងការអភិវឌ្ឍន៍ : ហិរញ្ញវត្ថុ វិស័យឯកជន និងវិនិយោគផ្ទាល់ពីបរទេស"** (Fuelling the Engines of Growth and Development : Finance, The Private Sector and Foreign Direct Investment) ។

អនុវត្តតាមកម្មវិធីនយោបាយ និងយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៣ ដែលបានផ្តល់អាទិភាពខ្ពស់ ដល់ការអភិវឌ្ឍន៍តំបន់តាមព្រំដែន និងតំបន់ជនបទ ដើម្បីប្រែក្លាយ

ឱ្យទៅជាតំបន់ដែលមានសន្តិភាព ស្ថិរភាព និងមានការអភិវឌ្ឍន៍ អាជ្ញាធរដែនដីខេត្តគ្រប់លំដាប់ថ្នាក់ បានខិតខំយកចិត្តទុកដាក់ ដឹកនាំ អនុវត្តការងារ សំដៅជំរុញការអភិវឌ្ឍន៍ខេត្តឱ្យមានការរីកចំរើន លើគ្រប់វិស័យ ដើម្បីធានាកំណើនសេដ្ឋកិច្ច និងបង្កើតការងារប្រកបដោយ សមធម៌ និងរួមចំណែក កាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ក្នុងរយៈពេលកន្លងមក ខេត្តស្វាយរៀងយើងខ្ញុំ បានផ្តោត ការយកចិត្តទុកដាក់យ៉ាងខ្លាំងលើការអភិវឌ្ឍន៍ផ្នែកហេដ្ឋារចនាសម្ព័ន្ធនានា ដែលជាកត្តាគន្លឹះក្នុងការ ជំរុញល្បឿននៃការអភិវឌ្ឍន៍សេដ្ឋកិច្ចសង្គម ជាអាទិ៍ រួមមាន : ហេដ្ឋារចនាសម្ព័ន្ធផ្លូវគមនាគមន៍ វិស័យអប់រំ វិស័យសុខាភិបាល ប្រព័ន្ធធារាសាស្ត្រ វិស័យកសិកម្ម ឧស្សាហកម្ម វិស័យវិនិយោគ ផ្នែកឯកជន ជាដើម ។ល។ ទន្ទឹមនេះ អាជ្ញាធរខេត្ត ក៏បានយកចិត្តទុកដាក់ផងដែរ ក្នុងការថែរក្សា ការពារ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សង្គមបានល្អប្រសើរជូនប្រជាពលរដ្ឋ ក៏ដូចជាបង្កើតបាននូវ បរិស្ថានអនុគ្រោះសំរាប់ការអភិវឌ្ឍន៍នានាលើគ្រប់វិស័យ ជាពិសេសវិស័យវិនិយោគឯកជន ។

*ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ជាទីគោរព !*

*អង្គសន្និសីទទាំងមូល ជាទីមេត្រី !*

ការជំរុញសន្ទុះក្បាលម៉ាស៊ីន កំណើន និងការអភិវឌ្ឍន៍ ដែលជាប្រធានបទនៃការពិភាក្សា នៅពេលនេះសំដៅទៅលើកត្តា**សំខាន់ ៣** គឺ :**ហិរញ្ញវត្ថុ វិស័យឯកជន និងវិនិយោគផ្ទាល់ពីបរទេស**។

**១-ផ្នែកហិរញ្ញវត្ថុ** (Finance) :

រាជរដ្ឋាភិបាលកម្ពុជា អាណត្តិទី៣ បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ សំរាប់ រយៈពេល៥ឆ្នាំ (២០០៦-២០១០) ដើម្បីជំរុញកំណើន បង្កើតការងារ ធានាសមធម៌ និងប្រសិទ្ធភាព ឆ្ពោះទៅសំរេចគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍កម្ពុជា ។ វិស័យហិរញ្ញវត្ថុដើរតួនាទីដ៏សំខាន់ ក្នុងស្ថេរភាពម៉ាក្រូសេដ្ឋកិច្ច និងក្នុងការកំណត់ល្បឿន និងទិសដៅរបស់កំណើនសេដ្ឋកិច្ច ដូច្នេះ ការយកចិត្តទុកដាក់វិស័យហិរញ្ញវត្ថុជាបញ្ហាសំខាន់បំផុត ដែលត្រូវតែពង្រឹងយន្តការនៃការគ្រប់គ្រង ប្រព័ន្ធហិរញ្ញវត្ថុឱ្យបានរឹងមាំ ប្រកបដោយតម្លាភាព មានគណនេយ្យភាពពេញលេញ និងមាន ប្រសិទ្ធភាព ហើយត្រូវពង្រីកសកម្មភាពផ្តល់សេវាហិរញ្ញវត្ថុឱ្យបានគ្រប់ទីកន្លែងដែលមានតម្រូវការ ពិសេសនៅតំបន់ជនបទក្នុងកំរិតអត្រាការប្រាក់សមស្រប និងធានាបាននូវអត្រាអតិផរណា ជាពិសេស ការផ្តល់សេវាឥណទានជនបទមានអត្រាការប្រាក់ទាប ដែលអាចប្រើប្រាស់បានសំរាប់អ្នកក្រីក្រ ដើម្បី បង្កើនប្រាក់ចំណូលរបស់ប្រជាជននៅតាមជនបទ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ក៏ប៉ុន្តែ ទន្ទឹមនឹងមានការផ្តល់សេវាហិរញ្ញវត្ថុនេះ យើងក៏ត្រូវមានការគិតគូរផងដែរនូវការបង្កើតការងារ ឬមុខរបរផ្សេងៗ ដល់ប្រជាជននៅតំបន់ជនបទ ដោយរិះរកគ្រប់វិធីសាស្ត្រ និងមធ្យោបាយសមស្រប ទៅតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង និងពេលវេលា ពិសេសស្របទៅតាមតំរូវការទីផ្សារនាពេល បច្ចុប្បន្ន និងទៅអនាគត ។ យើងកត់សំគាល់ឃើញថា ដំណើការអភិវឌ្ឍន៍ មានការរីកចំរើន ជាបណ្តើរៗរហូតមកដល់បច្ចុប្បន្ននេះ គឺអាស្រ័យដោយរាជរដ្ឋាភិបាលកម្ពុជា មានគោលនយោបាយ និងយុទ្ធសាស្ត្រត្រឹមត្រូវ បានធ្វើឱ្យមានការចាប់អារម្មណ៍ និងចូលរួមយ៉ាងផុលផុស ពីបណ្តាអង្គការ

សមាគម និងសហគមន៍ដៃគូអភិវឌ្ឍន៍នានា ទាំងក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ ក្នុងការជួយកសាង និងអភិវឌ្ឍន៍សេដ្ឋកិច្ច សង្គមកិច្ច ឱ្យមានការរីកចំរើនលើគ្រប់វិស័យ ឈានទៅរកការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋបានយ៉ាងឆាប់រហ័ស ។

**២-វិស័យឯកជន** (The Private Sector)

ខេត្តស្វាយរៀង កាលពីមុនជាខេត្តមួយមានលក្ខណៈអន់ថយខាងផ្នែកសេដ្ឋកិច្ច ប៉ុន្តែមកដល់បច្ចុប្បន្ននេះ ដោយមានការដឹកនាំដ៏ត្រឹមត្រូវពីរាជរដ្ឋាភិបាលកម្ពុជា ដែលមាន សម្តេចនាយករដ្ឋមន្ត្រី **ហ៊ុន សែន** ជាប្រមុខ បានធ្វើឱ្យទឹកដីខេត្តស្វាយរៀងមានការប្រែប្រួលមុខមាត់ថ្មី គួរជាទីមោទនៈ ។ រាជរដ្ឋាភិបាលបានបង្កើតឱ្យមានតំបន់សេដ្ឋកិច្ចពិសេសមួយកន្លែងរួចហើយ គឺ **តំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន(ស្វាយរៀង)** ដែលមានទីតាំងស្ថិតនៅក្នុងឃុំបាវិត និងឃុំបាទី ស្រុកចន្ទ្រា តាមបណ្តោយផ្លូវជាតិលេខ១ និងនៅជិតច្រកទ្វារព្រំដែនអន្តរជាតិបាវិត-ម៉ុកបាយ(តំបន់ព្រំដែនកម្ពុជា-វៀតណាម) ដែលទីតាំងភូមិសាស្ត្រនេះមានលក្ខណៈអំណោយផលល្អសំរាប់អ្នកវិនិយោគទុន ព្រោះថា មានប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ និងមានលក្ខណៈងាយស្រួលក្នុងការដឹកជញ្ជូន ដែលបច្ចុប្បន្ន មានក្រុមហ៊ុនវិនិយោគផ្ទាល់ពីបរទេស ចំនួន០៣ហើយ ដែលបាន និងកំពុងដំណើរការ គឺ : ក្រុហ៊ុន Best Way Industrial Co; Ltd ផលិតកង់ , ក្រុមហ៊ុន S-G-Y Steel International (Cambodia) Co; Ltd ផលិត វីស-ដែកប៊ូឡុង និងក្រុមហ៊ុន Kingmaker (Cambodia) Foot wear Co; Ltd ផលិតស្បែកជើង សំរាប់នាំចេញ ។ ក្រៅពីនេះ នៅក្នុងតំបន់ព្រំដែនបាវិត (កម្ពុជា-វៀតណាម) ក៏នៅមានរោងចក្រ សហគ្រាស សណ្ឋាគារ កាស៊ីណូ ជាច្រើនកន្លែងទៀត បាននិងកំពុងដំណើរការយ៉ាងមមាញឹក ដែលនេះ គឺជា កាលានុវត្តភាពដ៏វិសេសវិសាលបំផុតក្នុងការបង្កើតការងារជូនប្រជាជន និងជំរុញល្បឿនកំណើនសេដ្ឋកិច្ច សង្គមកិច្ច រួមចំណែកកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ ។ ជាក់ស្តែងបច្ចុប្បន្ននេះ បានផ្តល់ការងារដល់កម្មករ បានប្រមាណជាង ៥.០០០នាក់ហើយ ។

ការជំរុញលើកទឹកចិត្តវិស័យឯកជន គឺជាកម្លាំងចលករយ៉ាងសំខាន់ក្នុងការជំរុញល្បឿនកំណើនសេដ្ឋកិច្ច និងជាមូលដ្ឋានគ្រឹះ នៃគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា ។ ក្នុងការជំរុញការលើកទឹកចិត្តដល់ការអភិវឌ្ឍន៍វិស័យឯកជន រាជរដ្ឋាភិបាលកម្ពុជាបានបង្កើតឱ្យមានគណៈកម្មាធិការវិនិយោគនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានដើរតួជាអង្គភាពកណ្តាល ដើម្បីទាក់ទាញនិងសំរបសំរួលការវិនិយោគឯកជននៅកម្ពុជា ហើយនៅថ្នាក់ខេត្តមានអនុគណៈកម្មាធិការវិនិយោគខេត្ត ជាស្ថាប័នជួយសំរបសំរួលដល់កិច្ចការវិនិយោគផ្នែកឯកជនក្នុងដែនសមត្ថកិច្ចដែលខ្លួនទទួលខុសត្រូវ និងមានសិទ្ធិសំរេចផ្តល់ការវិនិយោគក្រោមទុនវិនិយោគ **២លាន**ដុល្លារអាមេរិក ។

តាមការសង្កេតជាក់ស្តែង ការវិនិយោគផ្នែកឯកជននៅកម្ពុជា ត្រូវបានធ្វើឡើងក្នុងវិស័យជាច្រើន ប៉ុន្តែវិស័យដែលគួរឱ្យកត់សម្គាល់ច្រើនជាងគេនោះគឺ ឧស្សាហកម្មកាត់ដេរ ទេសចរណ៍ ការងារសំណង់ ធនាគារ និង កសិដ្ឋានដំណាំ ហើយផ្នែកឯកជនក៏បានចូលរួមយ៉ាងសកម្មផងដែរក្នុងវិស័យអប់រំកំរិតឧត្តមសិក្សា ប៉ុន្តែលំហូរចូលនៃការវិនិយោគទៅក្នុងវិស័យអាទិភាព មានសភាព

យឺតយ៉ាវ ពិសេសវិស័យអាទិភាពមួយចំនួនដែលរាជរដ្ឋាភិបាលបានចាត់ទុកថាមានប្រៀបខ្លាំងក្នុងការ ប្រកួតប្រជែង និងអាចផ្តល់ចំណូលខ្ពស់ ដូជា **កសិកម្ម ការកែច្នៃកសិផល ហេដ្ឋារចនាសម្ព័ន្ធ** ។ល។ **ក្នុងន័យនេះខ្ញុំសូមស្នើអង្គសន្និសីទទាំងមូល មេត្តាចាប់អារម្មណ៍ និងជួយផ្តល់អនុសាសន៍** ធ្វើយ៉ាងណា ដើម្បីជំរុញ និងទាក់ទាញដល់ផ្នែកវិនិយោគឯកជន និងសហគមន៍អភិវឌ្ឍន៍នានា ឱ្យចូលមក បណ្តាក់ទុនវិនិយោគក្នុងវិស័យអាទិភាពដែលបានលើកឡើងខាងលើនេះ ព្រោះថាវិស័យកសិកម្ម និង ការកែច្នៃផលិតផលកសិកម្ម ពិសេសបច្ចេកទេសផលិតកម្មដំណាំគ្រប់ប្រភេទ និងបច្ចេកទេស នៃការ កែច្នៃនៅមានការខ្វះខាត និងមានលក្ខណៈអនថយនៅឡើយ បើប្រៀបធៀបទៅនឹងបណ្តាប្រទេស កំពុងអភិវឌ្ឍន៍នានាក្នុងតំបន់ និង នៅលើសកលលោក ។

**៣-<u>ការវិនិយោគផ្ទាល់ពីបរទេស</u>** (Foreign Direct Investment) :

ការវិនិយោគក្នុងវិស័យឯកជនរួមមានពីរផ្នែក គឺ **ការវិនិយោគក្នុងប្រទេស និងការវិនិយោគ ផ្ទាល់ពីបរទេស** ចំពោះការវិនិយោគផ្ទាល់ពីបរទេស ដែលបច្ចុប្បន្ន ភាគច្រើនស្ថិតនៅក្នុងផ្នែក ឧស្សាហកម្មសំលៀកបំពាក់ និងវិស័យទេសចរណ៍ ។ រាជរដ្ឋាភិបាលមានជំនឿថា ការវិនិយោគផ្ទាល់ ពីក្រៅប្រទេសអាចនឹងកើនឡើងដល់កំរិតមួយខ្ពស់ក្នុងអំឡុងពេល នៃផែនការយុទ្ធសាស្រ្តអភិវឌ្ឍន៍ ជាតិឆ្នាំ ២០០៦-២០១០ ហើយអាចនឹងមានសកម្មភាពខ្លាំងក្លា និងចម្រុះប្រភេទ ដើម្បីគ្របដណ្តប់ យ៉ាងទូលំទូលាយ និងស៊ីជំរៅលើផ្នែកអន្តរវិស័យជាច្រើន និងបែងចែកតាមតំបន់ភូមិសាស្រ្តនានា ហើយនិងប្រកបដោយចីរភាពក្នុងរយៈពេលវែង ។ រាជរដ្ឋាភិបាលនឹងធានាថា ប្រការនេះអាចសំរេច បានតាមរយៈកំណែទម្រង់រដ្ឋបាលសាធារណៈ និងកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ ដើម្បីបង្កើតនូវ បរិយាកាសមួយប្រកបដោយភាពងាយស្រួល និងមានការប្រកួតប្រជែង ហេតុដូចនេះកម្ពុជានឹងក្លាយ ជាប្រទេសដែលមានការលូតលាស់ និងប្រកបដោយសុវត្ថិភាព អាចព្យាករណ៍បាន និងមាន ផលចំណេញសំរាប់រយៈពេលវែងចំពោះការវិនិយោគផ្ទាល់ពីបរទេសទាំងឡាយ ។

ដូចដែលបានរៀបរាប់រួចមកហើយនៅក្នុងចំណុចទី២ខាងលើនេះរាជរដ្ឋាភិបាលកម្ពុជាបានយក ចិត្តទុកដាក់ជំរុញលើកទឹកចិត្ត ទាំងការវិនិយោគក្នុងប្រទេស និងការវិនិយោគផ្ទាល់ពីក្រៅប្រទេស ។ ដោយឡែក ក្នុងក្របខ័ណ្ឌអនុគណៈកម្មាធិការវិនិយោគខេត្ត មានសិទ្ធិសំរេចលើសំណើស៊ុំវិនិយោគ ដីសម្បទានសេដ្ឋកិច្ច ដែលមានទំហំក្រោម ១.០០០ហិកតា និងទុនវិនិយោគទាបជាង២លានដុល្លារ អាមេរិក និងបានជួយសំរបសំរួលបែបបទគតិយុត្តិក្នុងដំណើរការវិនិយោគ និងកិច្ចការធុរៈកិច្ច របស់ ក្រុមហ៊ុនវិនិយោគនានា ដែលបានចូលមកបណ្តាក់ទុនវិនិយោគនៅក្នុងខេត្តស្វាយរៀង ជាពិសេស នៅតំបន់អភិវឌ្ឍន៍ព្រំដែនបាវិត និងក្នុងតំបន់សេដ្ឋកិច្ចពិសេសមេនហាតធេន(ស្វាយរៀង) ជាក់ស្តែង កន្លងមក អនុគណៈកម្មាធិការវិនិយោគខេត្ត បានសំរេចផ្តល់ការវិនិយោគជូនក្រុមហ៊ុន Svay Rieng Cambodia Garment Co; Ltd ជាក្រុមហ៊ុនកាត់ដេរសំលៀកបំពាក់ ដែលមានកម្មករបំរើការងារជាង ១.០០០នាក់ ក្រៅពីនេះក្រុមហ៊ុន ទទួលបានការសំរេច ពីគណៈកម្មាធិការវិនិយោគ នៃក្រុមប្រឹក្សា អភិវឌ្ឍន៍កម្ពុជា ដោយមូលហេតុថា ក្រុមហ៊ុនទាំងនោះមានដើមទុនច្រើនជាង ២លានដុល្លារអាមេរិក ។

បញ្ហាប្រឈមនានា :

ទទួលមនិងសមិទ្ធផលដែលសំរេចបានជោគជ័យដូចបានលើកឡើងខាងលើ អនុគណៈកម្មាធិការវិនិយោគខេត្ត បានជួបប្រទះនឹងបញ្ហាប្រឈម ដូចជា : ក្រុមហ៊ុនភាគច្រើនដំឡើងទុនវិនិយោគឱ្យលើសពី២លានដុល្លារ ព្រោះនៅថ្នាក់ខេត្តគ្មានសិទ្ធិសំរេចឱ្យនាំចូលដោយរួចពន្ធនូវសំភារៈបរិក្ខាបំរើការវិនិយោគ សិទ្ធិនេះគឺស្ថិតនៅលើក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងមានសមត្ថកិច្ច ជាអ្នកសំរេច ។ ជាពិសេសការធ្វើប្រតិភូកម្មអំណាចមកឱ្យថ្នាក់ខេត្តនៅមិនទាន់មានភាពរលូន និងបានពេញលេញនៅឡើយ ដែលនេះ ជាបញ្ហាបង្កឱ្យមានភាពយឺតយ៉ាវដល់សិទ្ធិសំរេចនានា ជូនអ្នកវិនិយោគ ។

សំណូមពរ និងអនុសាសន៍ :

ឆ្លងតាមបទពិសោធន៍កន្លងមក ខ្ញុំសូមស្នើដល់អង្គសន្និសីទទាំងមូល មេត្តាជួយលើកជាយោបល់ស្នើសុំ ដល់គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធទាំងអស់ ក្នុងការធ្វើប្រតិភូកម្មអំណាច មកឱ្យថ្នាក់ខេត្ត ឱ្យបានពេញលេញ ដើម្បីឱ្យអាជ្ញាធរដែនដីខេត្ត មានលទ្ធភាពគ្រប់គ្រាន់ ក្នុងកិច្ចការអភិវឌ្ឍន៍ខេត្តរបស់ខ្លួន ជាពិសេសលើការងារវិនិយោគផ្នែកឯកជន និងដើម្បីជួយសំរួលបែបបទគតិយុត្តិជូនអ្នកវិនិយោគឱ្យបានលឿន និងកាត់បន្ថយការចំណាយសេវារដ្ឋបាលឱ្យមានលក្ខណៈសមស្រប នេះគឺជាការលើកទឹកចិត្តមួយផងដែរដល់អ្នកវិនិយោគទាំងឡាយ ដែលមាន បំណងចូលមកបណ្តាក់ទុនវិនិយោគនៅក្នុងប្រទេសកម្ពុជាយើង ហើយក៏ជាការសមស្របតាមគោលនយោបាយកំណែទម្រង់រដ្ឋបាលសាធារណៈផងដែរ ។

ជាទីបញ្ចប់នេះ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះគណៈអធិបតី និងសូមគោរពជូនពរ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី ព្រមទាំងសមាជិក សមាជិកា នៃអង្គសន្និសីទទាំងមូល សូមមានសុខភាពល្អ សំរេចបានជោគជ័យថ្មីៗថែមទៀត និងសូមបានជួបប្រទះនូវពរទាំងប្រាំប្រការ គឺ : អាយុ វណ្ណៈ សុខៈ ពលៈ និងបដិភាណៈ កុំបីឃ្លៀងឃ្លាតឡើយ ។

**សូមអរគុណ !**